**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា**

លេខៈ ៤៥៨ មស.[illegible]

# សេចក្តីណែនាំ

## ស្តីពី

## ការប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យា នៅគ្រឹះស្ថានបឋមសិក្សាសាធារណៈ

យោងអនុក្រឹត្យលេខ៣០៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការចាត់ចែងសេវាបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ លើលិខិតលេខ៥១៥ សហវ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសារាចរលេខ០២ អយក.សរចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការអនុវត្តអនុក្រឹត្យលេខ៣០៩ អនក្រ.បក ស្តីពីការគ្រប់គ្រងនិងការចាត់ចែងសេវាបង្រៀនក្នុងគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងក្នុងគោលបំណងពង្រឹងប្រសិទ្ធភាពលើការគ្រប់គ្រងនិងការប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ សូមធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡា និង មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ព្រមទាំងនាយកនៃគ្រឹះស្ថានបឋមសិក្សាសាធារណៈ ដូចខាងក្រោម៖

១. ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវចាត់ចែងធ្វើការណែនាំដល់គណៈគ្រប់គ្រងគ្រឹះស្ថានបឋមសិក្សាសាធារណៈទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ឲ្យធ្វើការប្រកាសអំពីចំនួនជាក់ស្តែងនិងឈ្មោះពិតប្រាកដរបស់គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យាដែលកំពុងបង្រៀននៅសាលាបឋមសិក្សាស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ផ្អែកលើគំរូប្រកាសដូចមានជូនភ្ជាប់ជាមួយឲ្យបានមុនថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៥ មកមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីពិនិត្យនិងស្នើសុំទិដ្ឋាការពីមន្ទីរមុខងារសាធារណៈពាក់ព័ន្ធ។

២. នាយកសាលាបឋមសិក្សានីមួយៗ ត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនចំពោះការប្រកាសអំពីចំនួនជាក់ស្តែងនិងឈ្មោះពិតប្រាកដរបស់គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យាដែលប្រើប្រាស់ក្នុងសាលា ផ្អែកលើនិយាមអប់រំដែលមានកំណត់នៅក្នុងអនុក្រឹត្យនិងសារាចរណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡាខាងលើ។ ក្នុងករណី នាយកសាលានីមួយៗបានធ្វើការប្រកាសត្រឹមត្រូវផ្អែកលើនិយាមអប់រំនិងមានការបញ្ជាក់អំពីការថយចុះនៃការប្រើប្រាស់ចំនួនគ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យា និងភាពមិនប្រក្រតីពាក់ព័ន្ធនឹងការប្រើប្រាស់នេះនឹងទទួលបានរង្វាន់ស្មើនឹង២(ពីរ)ខែនៃបៀវត្សលើចំនួនគ្រូបង្រៀនដែលត្រូវបានកាត់បន្ថយ។ ផ្ទុយទៅវិញ ក្នុងករណីការធ្វើអធិការកិច្ចនៅពេលក្រោយ ពិនិត្យឃើញថាការប្រកាសមានភាពមិនត្រឹមត្រូវ នាយកសាលានោះ នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន។

៤៣



អាសយដ្ឋានៈ (កែងផ្លូវម៉ៅសេទុងលេខ២០០៤) ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ ភ្នំពេញ ទូរស័ព្ទ.ទូរសារ(៨៥៥) ២៣ ៨៦៦ ៥០១

៣. មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ត្រូវពិនិត្យនិងផ្តល់ទិដ្ឋាការលើសំណើប្រើប្រាស់គ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យា យ៉ាងយូរ៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានសំណើរបស់មន្ទីរអប់រំ យុវជន និងកីឡា និងត្រូវចាត់ចែងរៀបចំការបើកផ្តល់ប្រាក់កម្រៃប្រចាំខែតាមតារាងបៀវត្សគ្រប់គ្រងដោយក្រសួងមុខងារសាធារណៈ។

៤. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវចេញសេចក្តីសម្រេចទទួលស្គាល់និងផ្តល់ប្រាក់កម្រៃគ្រូបង្រៀនថ្នាក់ពីរវេន គ្រូបង្រៀនថ្នាក់គួប និងគ្រូបង្រៀនជាប់កិច្ចសន្យា ដោយគិតចាប់ពីថ្ងៃដែលបានបង្រៀនជាក់ស្តែង បន្ទាប់ពីទទួលបានទិដ្ឋាការពីមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត។

ទទួលបាននូវសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡា និងមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ព្រមទាំងគ្រប់នាយកនៃគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវសហការអនុវត្តឲ្យបានសម្រេចនិងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២០១៥

| | | |
|---|---|---|
| រដ្ឋមន្ត្រី | រដ្ឋមន្ត្រី | រដ្ឋមន្ត្រី |
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ក្រសួងអប់រំ យុវជន និងកីឡា | ក្រសួងមុខងារសាធារណៈ |
| អូន ព័ន្ធមុនីរ័ត្ន | ហង់ ជួន ណារ៉ុន | ពេជ្រ ប៊ុនធិន |

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- មន្ទីរជំនាញរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ